# ប៊

**ប៊** តួអក្សរ ប ដូចគ្នា គ្រាន់តែពាក់ ត្រីសព្ទ (៊) នេះពីលើ ។ ខ្មែរសម្រាប់ប្រើជាសំនេរ ឧត្តម ដាក់ពីលើព្យញ្ជនៈ សិថិល-ឃោសៈ មានសំឡេងធំ សម្រាប់សរសេរឈ្មោះមនុស្ស ខ្លះ ដូចជាឈ្មោះ *ប៊ន, ប៊ិន, ប៊ី, ប៊ុត, ប៊ុន* ... និងឈ្មោះប្រទេស, ឈ្មោះក្រុង ... ដូចជា *ប៊ុលហ្គារ, ប៊ុលហ្គារី, ប៊ុយដាប៉េស្ត* Bulgar, Bulgarie, Budapest ។ល។ និងឈ្មោះវត្ថុជាភាសាបរទេសដែលខ្មែរយើងខ្ចីយកមកប្រើប៉ុណ្ណោះឯង ។ ឯពាក្យបរទេសដែលខ្មែរហៅតាមឈ្មោះដើមដែរ ត្រូវសរសេរដោយតួ ប៊ ព្រោះជាការចាំបាច់ណាស់ មានតិចតួចណាស់ ។ សម្រាប់ភាសាខ្មែរ, ចំណោមអក្សរមានសំឡេងតូច ៤ តួ គឺ *ប > ប៊, ស > ស៊, ហ > ហ៊, អ > អ៊* នេះ, *ស៊, ហ៊, អ៊* បីតួនេះ កាលបើផ្សំជាមួយនឹងស្រៈ *អិ, អី, អើ* ដែលមានសំឡេងធំជា *អ៊ិ, អ៊ី, អ៊ើ* សរសេរផ្សេងៗ *ឈ្មោះស៊ិន, ឈ្មោះហ៊ិន, ឈ្មោះអ៊ិន; ស៊ីផាយ, លេនហ៊ី, អ៊ីចឹង; សើចៗ* ... ប៉ុន្តែដើម្បីសម្រួលកុំឲ្យច្រឡំគ្នាពេក, ត្រូវសរសេរ *ឈ្មោះស៊ុន, ឈ្មោះហ៊ុន, ឈ្មោះអ៊ុន; ស៊ុផាយ, លេនហ៊ុ, អ៊ុចឹង, សើចៗ* ... ចំពោះតែពាក្យ ឯតួ ប៊ នេះនោះ ផ្សំជាមួយនឹងស្រៈ *អិ, អី,* នោះក៏ដោយ អ្នកសរសេរក៏គុំ អាចប្រើជា *ប៉ុ, ប៉ី* ឲ្យប្រាកដនឹង *ប៉* ទៀត, ដូចជាឈ្មោះ *ប៊ិន* កុំសរសេរ *ប៉ុន*, ឈ្មោះ *ប៊ី* កុំសរសេរ *ប៉ី* ព្រោះកុំឲ្យច្រឡំនឹងពាក្យថា *ប៉ុនធ្វើការ, ប៉ុនប្រសប់; ផ្ទុំប៉ី, ប៉ីតក; ចក់ប៉ី; ផ្លុំប៉ី* ជាដើម ។

**ប៊ឺ** ន. (បា. Beurre ) ខ្លាញ់ទឹកដោះ ខ្លាញ់គោ-ជាតិ (ជាឈ្មោះគោរសមួយប្រភេទ ដែលគេធ្វើកើតតាមសម័យ-និយម) : *ខ្លាញ់ប៊ឺ* ។

**ប៊ិក** ន. (បា. Bic ជាសញ្ញាដែខ្មៅដៃមានដំរាជាទឹកសរសេរមួយបែប Crayon à bille *ក្រេយ៉ុង ការប៊ីយ* «ខ្មៅដៃគ្រាប់») ខ្មៅដៃសម័យថ្មី មានច្រើនបែបដែលសរសេរចេញទឹកពណ៌ដូចវ៉ាកការស្រួប, ទោះបីជាក់សញ្ញាអ្វីដទៃទៀតនោះ ក៏ខ្មែរយើងហៅជាសាធារណៈថា *ប៊ិក* ដូចជា: *ប៊ិក-ខៀវ, ប៊ិកក្រហម, ប៊ិកបៃតង* ។



**ប៊ីស្ឃីត** (ប៊ីសគិ) ន. (បា. Biscuit) «នំដែលចម្អិនពីរដង») ឈ្មោះនំក្រៀមមានរូបសណ្ឋានជាបន្ទះៗ ស្តើងតូចៗមានបែបផ្សេងៗគ្នា មានរសជាតិផ្អែមខ្លះមិនផ្អែមខ្លះដាក់ដាក់ក្នុងប្រអប់ ទុកបានយូរ មានប្រភពដើមពីបរទេស ក្រោយមកកាន់ប្រទេសកម្ពុជា ត្រាតែអ្នកប្រទេសនេះចេះធ្វើកើតបានច្រើនយ៉ាង: *នំប៊ីស្ឃីតជាចំណីសម្រាប់ប្រើជាស្បៀងក្នុងការធ្វើដំណើរឆ្ងាយបានងាយស្រួល* ។

**ប៊ីហ្វតិក** (ប៊ីហ្វ-តិក) ន. (បា. Bifteck) សាច់គោចៀន (ជាឈ្មោះម្ហូបអាហារ តំរូវតាមច្បាប់មួយប្រភេទមានប្រភពពីបរទេស ក្រោយពេញនិយមក្នុងនានាប្រទេស) ។

**ប៊ិះ** កិ. វិ. (ក. សា.) ជ្រិះ, ផិះ, ទៀប, ជិត : *កាលពីតាងីតូដ្ឋមកប៊ិះនឹងត្រៀវ; ប៊ិះនឹងធ្លាក់ពីលើផ្ទះ, ឈឺធ្ងន់ប៊ិះនឹងស្លាប់* ។

**ប៊ីដុង** ន. (បា. Bidon ) ផ្តិល ឬល័ក្ខខ័ណ មានគម្របជាប់ស្រេច មានខ្សែសម្រាប់កាន់យួរឬស្ពាយក៏បាន សម្រាប់ដាក់ទឹកផ្ញើក្នុងការធ្វើដំណើរ : *ទឹកមួយប៊ីដុងនេះសម្រាប់ប្រើបានតែម្នាក់ទេ, ក្រុមយោធាតែងប្រើប៊ីដុង* ។

**ប៊ីយេរ** ឬ **ប៊ីយែរ** ន. ឈ្មោះគ្រឿងស្រវឹងមួយប្រភេទ មានប្រភពពីបរទេស (បា. Bière) ខ្មែរភាគច្រើនហៅប៊ីយែរប្រ-ពាននេះថា *ស្រាបៀ* (អ. Beer), អ្នកខ្លះហៅ *ឡាប៊ីយេរ*, ខ្លះហៅ *ឡាប៊ីយែរ* ក្លាយសំឡេងមកពី បា. La bière ដូច្នេះ ។

**ប៊ិត** ន. ឈ្មោះល្បែងមួយប្រភេទមានសម្បុរលឿង (ស. *ប៊ុសកំម* អ. ថ. *ប៊ុត-សៈកំម* ឬ *ប៊ុត-ស្រាទំម*) ។

**ប៊ឺះ** (ម. ក. *ពុំះ* ឬ *ប៉ុះ*) ។